# រោគរលាកថ្លើមប្រភេទ C
## (Hepatitis C)

រោគរលាកថ្លើមប្រភេទ C អាចបណ្ដាលមកពីមេរោគវីរើស ដែលជាមេរោគបណ្ដាលអោយមានជម្ងឺថ្លើម។  មេរោគវីរើសដែលបណ្ដាលឲ្យកើតរោគរលាកថ្លើមប្រភេទ C ច្រើនមាននៅក្នុងឈាម និងថ្លើមរបស់មនុស្សដែលមានរោគរលាកថ្លើមប្រភេទ C ។

ភាគច្រើន មេរោគវីរើសឆ្លងដោយសារឈាម។ មនុស្សដែកលអាចឆ្លងរោគនេះបាន គឺច្រើនជាអ្នកដែលទទួលការបញ្ចូលឈាម ឬការប្ដូរគ្រឿងក្នុងពីមុនឆ្នាំ១៩៩២ ឬអ្នកដែលប្រើម្ជុលចាក់ថ្នាំរួមគ្នា (ឧទាហរណ៍ ដូចជាអ្នកប្រើម្ជុលចាក់បញ្ចូលគ្រឿងញៀនរួមគ្នាជាដើម)។ ចាប់តាំងពីខែកក្កដា ឆ្នាំ ១៩៩២ មក ឈាមដែលត្រូវបញ្ចូលឲ្យអ្នកជម្ងឺ បានត្រូវពិនិត្យមើលយ៉ាងច្បាស់លាស់ ដើម្បីកុំឲ្យមានមេរោគវីរើសនេះ ហើយបានត្រូវចាត់ទុកថា ពុំមានគ្រោះថ្នាក់អ្វីឡើយ។

មេរោគវីរើសរលាកថ្លើមប្រភេទ **C** អាចឆ្លងនៅពេលណាដែលមានឈាម ឬវត្ថុរាវមានលាយឈាម ប៉ះនឹងស្បែកដែលមុត ឬរលាត់។  ការឆ្លងនេះអាចកើតឡើងបាន ទោះបីជាស្បែកដែលមុតនោះ មានទំហំតូច មើលពុំឃើញក៏ដោយ។  មេរោគនេះក៏អាចឆ្លងដោយសារការរួមភេទបានដែរ, ប៉ុន្តែ ការឆ្លងរបៀបនេះ មិនអាចកើតឡើងបានងាយៗ ដូចជា មេរោគអេចអាយវី ដែលបង្កើតជម្ងឺអេដស៍ នោះឡើយ។

មេរោគវីរើសរលាកថ្លើមប្រភេទ **C** មិនអាចឆ្លងបានដោយសារ ការអោបរឹត, កន្ដាស់, ក្អក, ឬការទទួលទានអាហាររួមគ្នានោះឡើយ។ ហើយ លោកអ្នកក៏មិនអាចឆ្លងមេរោគនេះ ដោយសារការផ្ដល់ឈាមនោះដែរ។

រោគរលាគថ្លើមប្រភេទ **C** អាចជារោគមួយដែលធ្ងន់ធ្ងរជាទីបំផុត។ មនុស្សភាគច្រើន ដែលកើតរោគនេះ អាចមានផ្ទុកមេរោគនេះ អស់មួយជីវិត។ មនុស្សមួយចំនួនដែលមានរោគរលាកថ្លើមប្រភេទ C អាចធ្វើឲ្យខូចថ្លើមហើយ ធ្លាក់ខ្លួនឈឺជាទម្ងន់។  អ្នកខ្លះទៀត ប្រហែលជានៅមានសុខភាពរឹងមាំ បន្ទាប់ពីមានរោគរលាកថ្លើមប្រភេទនេះ។  ជាទីបំផុត មេរោគរលាកថ្លើមប្រភេទ **C** អាចបណ្ដាល អោយអ្នកជម្ងឺ កើតជម្ងឺក្រិនថ្លើម ឬមហារីកថ្លើម។  នៅពេលដែលមនុស្សភាគច្រើនពុំមានជម្ងឺខូច ថ្លើម ឬជម្ងឺមហារីកថ្លើម យើងពុំអាចដឹងច្បាស់ថា តើនរណាម្នាក់និងមានរោគនេះ ឬពុំមានឡើយ។

អ្នកដែលអាចកើតរោគរលាកថ្លើមប្រភេទ **C** បាន គឺអ្នកដែល៖

- ប្រើគ្រឿងញៀន ឬប្រើម្ជុលរួមគ្នា ទោះបីជាប្រើតែមួយដងក៏ដោយ។
- បានទទួលការបញ្ចូលឈាម, អ្វីដែលធ្វើពីឈាម, ឬប្តូរគ្រឿងក្នុងថ្មី មុនខែកក្កដា ឆ្នាំ១៩៩២។
- បានរួមរ័ក្សជាមួយគូរដៃច្រើន, ជាពិសេស ប្រសិនបើអ្នកនោះពុំមានប្រើស្រោមអនាម័យសំរាប់ការពារ។
- ធ្វើការផ្នែកសុខាភិបាល ដូចជា វេជ្ជៈបណ្ឌិត ឬគ្រូពេទ្យជាដើម គឺអ្នកដែលអាចប៉ះពាល់ឈាម ឬម្ជុលចាក់ថ្នាំ។
- ទារកដែលកើតពីម្តាយដែលមានរោគរលាកថ្លើមប្រភេទ **C**។
- ធ្លាប់ទទួលការលាងឈាម។

ជួនកាល ថ្នាំម៉្យាងហៅថា interferon អាចប្រើសំរាប់ព្យាបាលរោគរលាកថ្លើមប្រភេទ **C** បាន។ ភាគច្រើនថ្នាំនេះ ប្រើរួមគ្នាជាមួយថ្នាំផ្សេងទៀតបាន ដូចជាថ្នាំ Ribavirin។ អ្នកមាន រោគរលាកថ្លើមប្រភេទ **C** ពុំគួរទទួលទានសុរា ឬលេបថ្នាំប្រភេទណាមួយដែលអាចធ្វើអោយខូចថ្លើមឡើយ។ អ្នកដែលមានរោគរលាកថ្លើមប្រភេទ **C** គួរទទួលចាក់ថ្នាំការពាររោគរលាកថ្លើមប្រភេទ A&B, ដែលជាមេរោគវ៉ីរើសពីរប្រភេទទៀត ធ្វើអោយខូចថ្លើមដែរ។ ថ្នាំផ្សះ អង់ទីប្យូទិក (Antibiotics) ក៏ពុំអាចមានលទ្ធភាពប្រឆាំងទប់ទល់ជាមួយមេរោគវ៉ីរើសរលាកថ្លើមប្រភេទ C បានឡើយ។ សូមមេត្តាពិភាក្សាជាមួយគ្រូពេទ្យរបស់លោកអ្នក អំពីវិធីព្យាបាលផ្សេងៗដែលអាចដែលមាន និងវិធីផ្សេងៗទៀត ដែលលោកអ្នកអាចអនុវតដើម្បីការពារកុំឲ្យខូចថ្លើមបាន។

ក្នុងពេលបច្ចុប្បន្ននេះ ពុំមានថ្នាំអ្វីសំរាប់ចាក់ការពាររោគរលាកថ្លើមប្រភេទ C ឡើយ។ មធ្យោបាយប្រសើរបំផុតក្នុងការការពារកុំឲ្យកើតរោគនេះ គឺការជៀសវាងកុំឲ្យមានប៉ះពាល់ឈាម។ នេះគឺបានន័យថា កុំប្រើម្ជុលចាក់ថ្នាំ, ប្រដាប់កោរពុកមាត់ ឬច្រាស់ដុសធ្មេញរួមគ្នា។ មន្ទីរទទួលអំណោយឈាម ឥឡូវនេះបានធ្វើការពិនិត្យឈាមកុំឲ្យមានមេរោគរលាកថ្លើមប្រភេទ C យ៉ាងដិតដល់។ ដូច្នេះការអាចឆ្លងរោគតាមការបញ្ចូលឈាមថ្មី គឺមានតិចតួចស្តួចស្តើងណាស់។ លោកអ្នកអាចឆ្លងមេរោគរលាកថ្លើមប្រភេទ C តាមការរួមរ័ក្ស ការប្រើស្រោមអនាម័យអាចជួយបន្ថយកុំឲ្យមានឆ្លងរោគនេះបាន។

- សូមកុំប្រើម្ជុលរួមគ្នា ប្រសិនបើចាក់គ្រឿងញៀន។ កុំប្រើបំពង់ហឺតថ្នាំញៀនកូកេនរួមគ្នា ពីព្រោះវាអាចមានជាប់ឈាមមកជាមួយ។ គួរស្រាវជ្រាវរកកម្មវិធីដែលអាចជួយកុំឲ្យអ្នកប្រើគ្រឿងញៀន។
- ប្រើស្រោមអនាម័យរាល់ពេលរួមរ័ក្សគ្នា។

- ប្រសិនបើចង់ឆ្លាក់ តាធូ (Tattoos) ឬចោះក្រវិល សូមឆ្លាក់ឬចោះតែនៅកន្លែងណាដែលមានច្បាប់អនុញ្ញាតិ និងមានប្រើប្រដាប់លាងត្រឹមត្រូវ។
- ចំពោះបុគ្គលិកធ្វើការក្នុងមន្ទីរពេទ្យឬលាងសំអាតមន្ទីរពេទ្យ គួរប្រើអនុវត្តវិធីលាងសំអាតទៅតាមក្បួនត្រឹមត្រូវ។
- ប្រសិនបើ អ្នកកើតរោគរលាកថ្លើមប្រភេទ C សូមកុំប្រើប្រដាប់កោរពុកមាត់ ឬច្រាស់ដុសធ្មេញរួមគ្នាជាមួយអ្នកដទៃ។
- ប្រសិនបើ អ្នកកើតរោគរលាកថ្លើមប្រភេទ C៖ សូមកុំផ្តល់អំណោយឈាម, មេជីវិត, ឬគ្រឿងក្នុង។

មានមេរោគវីរើសជាច្រើនដែលបណ្តាលឲ្យកើតរោគរលាកថ្លើម។ ប្រសិនបើលោកអ្នកមានរោគរលាកថ្លើមដែតមួយប្រភេទ លោកអ្នកនៅតែអាចកើតរោគនេះប្រភេទផ្សេងៗទៀតបានដែរ។

រោគរលាកថ្លើមប្រភេទ A អាចឆ្លងតាមលាមកពីអ្នកដែលលោកអ្នកប៉ះពាល់, អាហារនិងទឹកដែលមានមេរោគ។  សូម្បីដែលលាមកតូចមួយក៏ដោយ ក៏វាអាចមានជាប់មេរោគបានដែរ។ មានថ្នាំចាក់សំរាប់ការពាររោគរលាកថ្លើមប្រភេទ A។ មេរោគវីរើសរលាកថ្លើមប្រភេទ B ឆ្លងតាមឈាមនិងវត្ថុរាវក្នុងរាងកាយ ដូចជាទឹកកាម។ រោគរលាកថ្លើមប្រភេទ B ក៏មានថ្នាំសំរាប់ចាក់ការពារបានដែរ។ ប្រសិនបើលោកអ្នកមានរោគរលាកថ្លើមប្រភេទ C៖ សូមមេត្តាសាកសួរគ្រូពេទ្យរបស់លោកអ្នកដើម្បីឲ្យគាត់ចាក់ថ្នាំការពាររោគរលាកថ្លើមប្រភេទ A និងប្រភេទ B ជូនលោកអ្នក។ ម្យ៉ាងទៀតការធ្វើតែស៍ឈាមក៏អាចជួយឲ្យលោកអ្នកដឹងថាតើ លោកអ្នកមានរោគរលាកថ្លើមប្រភេទ C ឬពុំមានបានដែរ។

ចំពោះពត៌មានបន្ថែម លោកអ្នកអាច៖

- សាកសួរវេជ្ជបណ្ឌិតឬគ្រូពេទ្យរបស់លោកអ្នក
- ក្រសួងសុខាភិបាលប្រចាំតំបន់លោកអ្នក
- ក្រសួងសាធារណៈសុខាភិបាលនៃរដ្ឋម៉ាស្សាឈូសេត ផ្នែកជម្ងឺឆ្លងនិងការចាក់ថ្នាំបង្ការរោគ ទូរស័ព្ទលេខ (617) 983-6800 ឬ ទូរស័ព្ទដោយពុំចេញថ្លៃ លេខ (888) 658-2850 ឬអានវិបសៃអាសយដ្ឋាន http://www.mass.gov/dph ។

*ពត៌មាននេះដកស្រង់នឹងបកប្រែចេញពីពត៌មាននៃក្រសួងសាធារណៈសុខាភិបាលប្រចាំ រដ្ឋម៉ាស្សាឈូសេត ដោយមណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។*